**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃនេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រារព្ធពិធីផ្ទេរប្រគល់កូនសោរជានិមិត្តរូបនៃមន្ទីរឃុំឃាំងរបស់សាលាក្តីខ្មែរក្រហមជូនទៅ**ឯកឧត្តម គុយ ប៊ុនសន** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ។ ពិធីនេះគឺជាដំណាក់កាលដ៏សំខាន់មួយក្នុងការរៀបចំអោយមានការកាត់ក្តីនាពេលខាងមុខនេះ។ ពិធីផ្ទេរប្រគល់នេះបានប្រព្រឹត្តធ្វើឡើងក្រោមអធិបតីភាពរបស់ **ឯកឧត្តម ក្រាញ់ តូនី** ប្រធានការិយាល័យរដ្ឋបាលស្តីទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

យោងទៅតាមមាត្រាទី ២៤ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៍ ៦ ខែ មិថុនា ឆ្នាំ ២០០៣ និងមាត្រាទី ៩ នៃកិច្ចព្រមព្រៀងបន្ថែមលើសុវត្ថិភាពនិងការរៀបចំសន្តិសុខ ចុះហត្ថលេខាកាលពីថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៦ ការគ្រប់គ្រងលើអ្នកជាប់ឃុំរបស់សាលាក្តីខ្មែរក្រហមគឺជាភារកិច្ចទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា។

យើងសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលឥណ្ឌានិងជប៉ុនដែលបានផ្តល់ជំនួយក្នុងការសាងសង់មន្ទីរឃុំឃាំងឲ្យមានកំរិតស្តង់ដារអន្តរជាតិ។ ការសាងសង់បានប្រព្រឹត្តធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយនឹងគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហមលើផ្នែកគំនិតនិងការរចនាអាគារ។ មន្ទីរឃុំឃាំងនេះ មាន**លោក គិម ជួន** ជាប្រធានដោយមានការគាំទ្រពីសំណាក់អនុប្រធានមួយរូប រួមទាំងអ្នកយាមមួយក្រុម។ ការរៀបចំផ្សេងៗកំពុងដំណើរការដើម្បីធានាឲ្យមានសុវត្ថិភាព ការគាំទ្រផ្នែកសុខភាពនិងអាហារសំរាប់បុគ្គលណាដែលត្រូវឃុំខ្លួនតាមការបង្គាប់របស់ដីការឃុំខ្លួនបណ្តោះអាសន្ន ចេញដោយសហចៅក្រមស៊ើបអង្កេត។

ពិធីប្រគល់មន្ទីរឃុំឃាំងនេះគឺជាជំហានដ៏មានសារៈសំខាន់មួយក្នុងការត្រៀមខ្លួនសំរាប់ដំណើរការរកយុត្តិធម៌ដែលនឹងកើតមានក្នុងពេលឆាប់ៗខាងមុខនេះ។

សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង**លោករាជ សម្បត្តិ** មន្ត្រីទទួលបន្ទុកព័ត៌មាន តាមរយៈទូរស័ព្ទលេខ 012 488 156 ឬតាមរយៈសារអេឡិចត្រូនិក reach.sambath@eccc.gov.kh, និង reachsambath@hotmail.com

ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០៧